វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺ៖

- ការនាំចេញកៅស៊ូរបស់កម្ពុជាកើនឡើង ២៣% ក្នុងរយៈពេលប្រាំបួនខែនៅឆ្នាំ២០១៩
- ប្រទេសវៀតណាមសរសើរកិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់ខ្លួន ធ្វើឱ្យជំរុញការវិនិយោគបរទេស
- សម្រាប់សេដ្ឋកិច្ចសហរដ្ឋអាមេរិក អ្នកប្រើប្រាស់គឺជាអ្នកការការពារដ៏ល្អបំផុត សម្រាប់ទប់ទល់នឹងឱនភាពសេដ្ឋកិច្ច

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការនាំចេញកៅស៊ូរបស់កម្ពុជាកើនឡើង ២៣% ក្នុងរយៈពេលប្រាំបួនខែនៅឆ្នាំ២០១៩

យោងតាមការចេញផ្សាយរបស់អគ្គនាយកដ្ឋានកៅស៊ូនៅក្រសួងរុក្ខាប្រមាញ់ និងនេសាទ កាលពីថ្ងៃព្រហស្បតិ៍ កម្ពុជាបាននាំចេញកៅស៊ូស្ងួតចំនួន ១៧៣ ០៧២ តោន ក្នុងអំលុងពេលប្រាំបួនខែនៅឆ្នាំ២០១៩ កើនឡើងប្រមាណជា ២៣% បើធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៨។

ការនាំចេញនេះបានរកចំណូលអោយកម្ពុជា ២៣១លានដុល្លារសហរដ្ឋអាមេរិក។ តម្លៃរបស់កៅស៊ូស្ងួតជាមធ្យម ១ ៣៣៥ ដុល្លារ សហរដ្ឋអាមេរិកក្នុងមួយតោន ទាបជាងតម្លៃឆ្នាំ២០១៨ ចំនួន ២៩ដុល្លារអាមេរិក។

កម្ពុជានាំចេញកៅស៊ូទៅកាន់ប្រទេសសំខាន់ៗមួយចំនួនដូចជា ម៉ាឡេស៊ី វៀតណាម សឹង្ហបុរី និងចិន។

ផ្ទៃដីដាំដុះកៅស៊ូសរុបនៅប្រទេសកម្ពុជាមានប្រហែល ៤៣៤ ៥៥២ ហិកតា ដែលនៅក្នុងនោះ ៥៤% ជាកៅស៊ូដែលមានអាយុគ្រប់គ្រាន់អាចប្រមូលផលបាន។

### តារាងប្រចាំសប្តាហ៍៖ កំណើនផ.ស.ស របស់កម្ពុជានាំមុខគេនៅក្នុងចំណោមប្រទេសដៃគូ

តារាងសប្តាហ៍នេះបង្ហាញអោយឃើញថា ក្នុងឆ្នាំនេះ និងឆ្នាំខាងមុខ កំណើនសេដ្ឋកិច្ចកម្ពុជាមានសន្ទុះលឿនជាងគេក្នុងចំណោមបណ្តាប្រទេសទាំងអស់នៅអាស៊ីអាគ្នេយ៍។ កំណើនសេដ្ឋកិច្ចជាមធ្យមរបស់កម្ពុជាប្រចាំឆ្នាំចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២០ មានប្រហែល ៧,១% បន្ទាប់មកប្រទេសវៀតណាម ៦,៩% និងប្រទេសមីយ៉ាន់ម៉ា ៦,៧%។ កណើន ផ.ស.ស នៅអាស៊ីអាគ្នេយ៍

ទាំងមូលត្រូវបានគេរំពឹងថា នឹងធ្លាក់ចុះពី៥,១% ក្នុងឆ្នាំ២០១៨ មកត្រឹម ៤,៧% ក្នុងឆ្នាំ២០២០។

**តារាងប្រចាំសប្តាហ៍៖ ការព្យាករណ៍កំណើន ផ.ស.ស នៅអាស៊ីអាគ្នេយ៍**




*ប្រភព៖ [Asian Development Bank, 2019 Outlook Update]*

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## ប្រទេសវៀតណាមសរសើរកិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់ខ្លួនដែលជំរុញឱ្យមានការវិនិយោគបរទេស

[យោងតាមកាសែតភ្នំពេញប៉ុស្តិ៍]បានឱ្យដឹងថា ប្រទេសវៀតណាមកំពុងលើកកម្ពស់នូវកិច្ចព្រមព្រៀងពាណិជ្ជកម្ម ដ៏ទូលំទូលាយរបស់ខ្លួន ដើម្បីទាក់ទាញការវិនិយោគបរទេស។ ប្រទេសនេះបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសំខាន់ៗចំនួនពីរ ដើម្បីជំរុញការទាក់ទាញវិនិយោគ គឺកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយនិងវឌ្ឍនភាពសម្រាប់ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (CPTPP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអឺរ៉ុប - វៀតណាម (EVFTA) ។

CPTPP គឺជាតំបន់ពាណិជ្ជកម្មសេរីធំជាងគេទីបីនៅលើពិភពលោក តាមរយៈផលិតផលក្នុងស្រុកសរុប បន្ទាប់ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាមេរិកខាងជើង និងទីផ្សារអឺរ៉ុបរួម។ កិច្ចព្រមព្រៀងនេះផ្តល់ជូនអាជីវកម្មដែលមកពីសហគមន៍អឺរ៉ុប និងប្រទេសចំនួន ១០ ដែលជាសមាជិកនៃ CPTPP រួមមានការលើកទឹកចិត្តជាច្រើន ជាពិសេសការកាត់ពន្ធផ្សេងៗ រួមជាមួយនឹងការចូលទៅកាន់ទីផ្សារដ៏ធំរបស់វៀតណាមដែលមានប្រជាជនប្រមាណ ៩៦ លាននាក់។
យោងតាមក្រសួងផែនការ និងការធ្វើវិនិយោគទុននៃប្រទេសវៀតណាមវិនិយោគិនសហភាពអឺរ៉ុបមានចំនួន ២ ២៤៤ គម្រោងនៅក្នុងប្រទេសវៀតណាមដែលមានដើមទុនចុះបញ្ជីសរុបចំនួន ២៤,៧ ប៊ីលានដុល្លារ។

# សេដ្ឋកិច្ចសកល

## សម្រាប់សេដ្ឋកិច្ចអាមេរិក អ្នកប្រើប្រាស់គឺជាអ្នកការការពារដ៏ល្អបំផុត សម្រាប់ទប់ទល់នឹងឱនភាពសេដ្ឋកិច្ច

ទោះបីជាសង្គ្រាមពាណិជ្ជកម្មជាមួយចិន ហានិភ័យនយោបាយសំខាន់ៗ និងភាពមិនច្បាស់លាស់ជាច្រើនសម្រាប់អាជីវកម្មក៏ដោយ ក៏សេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិកត្រូវបានគេរំពឹងថានឹងចៀសផុតពីឱនភាពនៃសេដ្ឋកិច្ច នៅឆ្នាំក្រោយនេះ ដោយសារតែភាគច្រើន អ្នកប្រើប្រាស់សហរដ្ឋអាមេរិចមានភាពស៊ាំនឹងវិបត្តិ បើយោងតាមសារព័ត៌មាន [Bloomberg Businessweek] ។

ការចំណាយរបស់អ្នកប្រើប្រាស់មានចំនួនជិត ៧០% នៃផ.ស.ស របស់សហរដ្ឋអាមេរិកដែលធ្វើឱ្យទម្លាប់ចំណាយមានសារៈសំខាន់ចំពោះកំណើនសេដ្ឋកិច្ច។ ការប្រើប្រាស់ទៅលើគ្រួសារបានកើនឡើង ៤,៦% ក្នុងអត្រាប្រចាំឆ្នាំ ចាប់ពីខែមេសាដល់ខែមិថុនាដែលជាល្បឿនលឿនបំផុត ចាប់តាំងពីត្រីមាសចុងក្រោយនៃឆ្នាំ ២០១៧ ។

ការងារ និងប្រាក់ចំណូលនៅសហរដ្ឋអាមេរិកបន្តកើនឡើង ហើយទំនុកចិត្តអ្នកប្រើប្រាស់នៅតែខ្ពស់។ ការលក់នៃថ្ងៃឈប់សម្រាក

សម្រាប់ឆ្នាំ ២០១៩ ត្រូវបានគេរំពឹងថានឹងកើនឡើងក្នុងចន្លោះពី ៣,៨ភាគរយ ទៅ ៤,២ភាគរយ ពីឆ្នាំ ២០១៨ កើនឡើងពីមធ្យម ៣,៧ភាគរយ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមានៈ ព័ត៌មានស្ថិតិ របស់ប្រទេសវៀតណាមនៅថ្ងៃអង្គារ និងការសម្រេចចិត្តលើអត្រាការប្រាក់ នៅសហរដ្ឋអាមេរិក ជប៉ុន និងហុងកុង។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយៈ

<u>ថ្ងៃច័ន្ទ ទី២៨ ខែតុលា</u>

- កំណើននៃកំចី នៅតំបន់អឺរ៉ុប សម្រាប់ខែកញ្ញា
- តុល្យភាពពាណិជ្ជកម្ម ទំនិញ នៅសហរដ្ឋអាមេរិក សម្រាប់ខែ កញ្ញា

<u>ថ្ងៃអង្គារ ទី ២៩ ខែតុលា</u>

- ទំនុកចិត្តអាជីវកម្ម របស់កូរ៉េខាងត្បូង សម្រាប់ខែ តុលា
- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ របស់ជប៉ុន សម្រាប់ខែតុលា
- តុល្យភាពពាណិជ្ជកម្ម របស់វៀតណាម សម្រាប់ខែ តុលា
- អតិផរណា របស់វៀតណាម សម្រាប់ខែ តុលា
- ផលិតកម្មឧស្សាហកម្ម របស់វៀតណាម សម្រាប់ ខែ តុលា
- សន្ទស្សន៍ថ្លៃនៃការផលិត របស់សឹង្ហបុរី សម្រាប់ខែ កញ្ញា

<u>ថ្ងៃពុធ ទី ៣០ ខែតុលា</u>

- ការលក់រាយ របស់ជប៉ុន សម្រាប់ខែ កញ្ញា
- អតិផរណា របស់អូស្ត្រាលី សម្រាប់ត្រីមាសទី៣ ឆ្នាំ ២០១៩
- សន្ទស្សន៍នៃតម្លៃការផលិត របស់ហ្វីលីពីន សម្រាប់ខែ កញ្ញា
- ការវិនិយោគផ្ទាល់ពីបរទេស នៅឥណ្ឌូនេស៊ី សម្រាប់ឆ្នាំ ២០១៩
- ទំនុកចិត្តរបស់អ្នកប្រើប្រាស់ នៅតំបន់អឺរ៉ុប សម្រាប់ខែ តុលា

<u>ថ្ងៃព្រហស្បត្តិ៍ ទី៣១ ខែតុលា</u>

- ការសម្រេចចិត្តលើអត្រាការប្រាក់ទុនបម្រុង របស់សហរដ្ឋអាមេរិក
- ផលិតកម្មឧស្សាហកម្ម របស់កូរ៉េខាងត្បូង សម្រាប់ខែ កញ្ញា
- ការលក់រាយ របស់កូរ៉េខាងត្បូង សម្រាប់ខែ កញ្ញា
- ការវិនិយោគមូលបត្រ បំណុលបរទេស របស់ជប៉ុន សម្រាប់ខែ តុលា
- ការសម្រេចចិត្តនូវអត្រាការប្រាក់ របស់ហុងកុង
- ការសម្រេចចិត្តលើអត្រាការប្រាក់ របស់ធនាគារជាតិជប៉ុន

<u>ថ្ងៃសុក្រ ទី០១ ខែវិច្ឆិកា</u>

- អតិផរណា របស់កូរ៉េខាងត្បូង សម្រាប់ខែ តុលា
- តុល្យភាពពាណិជ្ជកម្ម របស់កូរ៉េខាងត្បូង សម្រាប់ខែ តុលា
- អត្រានៃភាពគ្មានការងារធ្វើ របស់ជប៉ុន សម្រាប់ខែ កញ្ញា
- អត្រាអតិផរណា របស់ឥណ្ឌូនេស៊ី សម្រាប់ខែ តុលា
- អត្រានៃភាពគ្មានការងារធ្វើ របស់អាមេរិក សម្រាប់ខែ តុលា